

កត្តាច្បាស់លាស់អំពី ការបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារការបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ

- ផ្តល់ផលបំណាច់ ប៉ុន្តែពុំមានផ្តល់ការគាំពារអាជីវកម្ម (មុខងារ) ឬសិទ្ធិវិលត្រឡប់មកវិញនោះទេ
- ផ្តល់ផល់បុគ្គលិកនូវបំណាច់សំណងខ្ទះ។ ទៅលើការវ៉ៃទាំមាតាបិតា បុត្រាបុត្រី ស្វាមីភរិយា និងដៃគូរដែលមានភេទដូចគ្នា ឬការចំណាយពេលដើម្បីអោយមានទំនាក់ទំនងជិតស្និទជាមួយនឹងកូនដែលទើបនឹងបានទទួល
- ធានារ៉ាប់រងទៅលើបុគ្គលិកទាំងអស់ ដែលបានទទួលការរ៉ាប់រងដោយកម្មវិធី SDI (ឬគំរោងស្ម័គ្រចិត្ត ជំនួសកម្មវិធីSDI)
- ផ្តល់ផលបំណាច់រហូតដល់ទៅចំនួន 6 សប្តាហ៍ ទៅក្នុងកំឡុងពេល 12 ខែ
- ផ្តល់ផលបំណាបំណាច់នៃបាត់បង់ប្យេវត្ត (ប្រាក់ខែ)ដែលមានចំនួនប្រហែលជា 55 ភាគរយ
- ការដកហូតប្រាក់ខែ ចាប់ផ្តើមឡើងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2004
- ផលបំណាច់ចាប់ផ្តើមឡើងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2004
- ចាត់ចែងឡើងដោយ Employment Development Department

នៅក្នុងរដ្ឋកាលីហ្ហ្ន៉ីញ៉ា នេះគឺជាច្បាប់បញ្ញត្តិ

ការបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ

កម្មវិធីធានារ៉ាប់រង

ជាពេលដែលត្រូវផ្តល់ការយកចិត្តទុកដាក់

1-877-238-4373

ដើម្បីទទួលពត៌មានបន្ថែម សូមបើកមើលគេហទំព័រ :
www.edd.ca.gov

1-877-238-4373 (English)
1-877-379-3819 (Español)
1-800-563-2441 (TTY)

EDD ជានិយោកជន(ទីកន្លែងធ្វើការ)កម្មវិធីផ្តល់ឱ្យការសេ្នីគ្នា។
ការស្នើសុំពិសេស ទៅលើទ្រង់ទ្រាយផ្សេងទៀត ត្រូវធ្វើឡើងដោយទូរស័ព្ទទៅ ទូរស័ព្ទលេខ
1-877-238-4373

ក្នុងសៀវភៅតូចនេះ សំរាប់តែពត៌មានទូទៅ លើយពុំមានការអនុវត្ត
និងអនុភាពនៃហ៊ីច្បាប់បញ្ញត្តិ ក្រិតក្រម ឬបទបញ្ជាឡើយ។

DE 2511/B Rev. 2 (10-04) **(INTERNET)**



ជាពេលវេលា ដែលអ្នកត្រូវការ សំរាប់ពេលវេលា ដូចជាពេលនេះ

កម្មវិធីធានារ៉ាប់រង ការបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ (Paid Family Leave)។

រូមនឹងការបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ អ្នអាចលៃលកទៅទីកន្លែងដែលអ្នកត្រូវការទៅ

មានពេលខ្លះនៅក្នុងដំណើរជីវិតរបស់អ្នកប្រកបអាជីវកម្មត្រប់រូប គេត្រូវការពេលវេលាដើម្បីថែទាំអ្នកដែលគេស្រឡាញ់។ អាចជាមាតាដែលត្រូវការពេលវេលា ដើម្បីធ្វើអោយមានទំនាក់ទំនងជិតស្និទជាមួយនិងបុត្រដែលទើបតែនឹងប្រសូត្រមក។ អាចជាបុគ្គលិកដែល ត្រូវការថែទាំមាតាបិតា បុត្រស្វាមីភរិយា ប្ជុំដគូរដែលមានភេទដូចគ្នា ដែលកំពុងតែមានជម្ងឺជាទម្ងន់។ ច្បាប់បញ្ញត្តិរដ្ឋកាលីហ្វ័រនីញ៉ា ផ្នែកបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ បានបង្កើតឡើងសំរាបស្ថានភាពដូចនេះ។

កម្មវិធី ដែលមានផលប្រយោជន៍ដល់អ្នក និងក្រុមគ្រួសាររបស់អ្នក

ផលបំណាច់ធានា៉រាប់រងផ្នែកបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ គឺយោងទៅលើចំនួនទឹកប្រាក់រកបានប្រចាំត្រីមាស កន្លងមក ហើយអាចមានចំនួនតិចបំផុត ពី៥០ដុល្លារ ទៅចំនួនច្រើនបំផុត ៧២៨ដុល្លារ ក្នុង១សប្ដាហ៍ រហូតដល់ទៅកឹរិតចំនួន៦សប្ដាហ៍ ចំពោះការទាមទារដែលចាប់ផ្តើមឡើងនៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៤។ ចំពោះការទាមទារដែលធ្វើឡើងនៅក្នុងឆ្នាំ២០០៥ កឹរិតបំណាច់ចំនួនច្រើនបំផុតប្រចាំសប្ដាហ៍គឺចំនួន៨៤០ ដុល្លារ។

ការបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារសំរាប់បុគ្គលិករដ្ឋកាលីហ្វ័រនីញ៉ា

ការធានា៉រាប់រងផ្នែកបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ ពុំមានផ្តល់ការគាំពាអាជីវកម្ម (មុខងារ) ឬសិទ្ធិវិលត្រឡប់ មកវិញនោះទេ។ មុខងាររបស់អ្នកអាច ទទួលការគាំពារ បើសិនជានិយោកជន(កន្លែងធ្វើការ) របស់អ្នក ទទួលការតម្រូវអោយមានមាត្រាបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារផ្នែកសហព័ន្ធ Family Medical Leave Act និងមាត្រាសិទ្ធិគ្រួសារ California Family Rights Act។ អ្នកត្រូវតែផ្តល់ដំណឹងដល់និយោកជនរបស់អ្នក នូវមូលហេតុដែលឈប់សំរាកដែលសមស្របទៅនឹងក្រិតក្រមក្រុមហ៊ុនរបស់អ្នក។

ដើម្បីអោយមានលក្ខណ:សម្បត្តិទទួលសំណងប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ អ្នកត្រូវតែបំពេញទៅតាមការតម្រូវដូចខាងក្រោមនេះ :

- ទទួលការធារនា៉រាប់រងដោយផ្នែកធានា៉រាប់រងជនពិការ (SDI) (ឬគំរោងស្ម័ត្រចិត្ត ជំនួសកម្មវិធីSDI)ហើយរកប្រាក់បានយ៉ាងហោចណាស់ចំនួន៣០០ដុល្លារ ដែលបានទទួលការដកហូតទុក
- បំពេញក្រដាសទាមទារដោយត្រឹមត្រូវ ចប់សព្វគ្រប់ ពិត និងដោយទាន់ពេល
- ផ្តល់ពតិមានសុខភាព ដែលគាំទ្រការទាមទារ ថាអ្នកដែលទទួលការថែទាំពិតជាត្រូវការសេចក្តីថែទាំរបស់អ្នក
- ផ្តល់ឯកសារដើម្បីគាំទ្រការទាមទារដើម្បីធ្វើអោយមានទំនាក់ទំនងជិតស្និទជាមួយនិងបុត្រដែលទើបនឹងទទួល
- ប្រើកំណត់ពេលវិស្សមកាលដែលបានទទួល តែពុំទាន់បានប្រើប្រាស់ បើសិនជាមានការតម្រូវដោយវិនិយោកជនរបស់អ្នក
- កំណត់ពេលរង់ចាំទទួលប្រាក់ គឺមានចំនួន៧ថ្ងមុនពេលបំណាច់ទាំងនេះ ចាប់ផ្តើមឡើង

អ្នកអាចពុំមានសិទ្ធទទួល បើសិនជា :

- ទទួលការធានា៉រាប់រងផ្នែកពិការប្រចាំពីរដ្ឋាភិបាលខេត្ត សំណងធានា៉រាប់រងផ្នែកឥតការងារធ្វើ ឬសំណងផ្នែកបុគ្គលិក
- អ្នកពុំប្រកបការងារអ្វី ឬរិះរកការងារ នៅក្នុងពេលដែលអ្នកចាប់ផ្តើមឈប់សំរាកដោយភារ:កិច្ចគ្រួសារ
- អ្នកពុំមានទទួលការខាតបង់ ដោយបាត់បង់ប្រាក់ខែ
- សេចក្តីត្រូវការទៅលើការថែទាំ ពុំមានការគាំទ្រដែលបញ្ជាក់ឡើងដោយវេជ្ជបណ្ឌិត ឬវេជ្ជបណ្ឌិតជំនួយ
- អ្នកជាប់ឃុំឃាំង ដោយជាប់ទោសឧក្រិដ្ឋកម្ម

អ្នកមានសិទ្ធទទួល :

- ដឹងពីមូលហេតុ និងមូលដ្ឋាននៃការសំរេចណាមួយ ដែលប៉ះពាល់ទៅដល់ផលណាច់ទាំងអស់របស់អ្នក
- សុំអោយមានការវិនិច្ឆ័យសារជាថ្មីទៅលើការសំរេចឺនសិទ្ធិទទួលផលបំណាច់របស់អ្នក ហើយបង្ហាញខ្លួននៅចំពោះមុខចៅក្រម ផ្នែកចាត់ចែងច្បាប់បញ្ញត្តិគណ:កម្មាធិការនាយក
- ការសម្ងាត់ - ពតិមានអំពីការគ៉ារបស់អ្នកនឹងរក្សាជាសម្ងាត់ លើកលែងតែគោលបំណងបានអនុញ្ញាត្តិឡើងតាមច្បាប់

ច្បាប់បញ្ញត្តិពិសេស សំរាប់ពេលវេលាពិសេស

ការធានា៉រាប់រងបង់ប្រាក់សំរាប់ការឈប់សំរាកដោយភារ:កិច្ចគ្រួសារ រដ្ឋកាលីហ្វ័រនីញ៉ាជារដ្ឋដំបូងបង្អស់នៅក្នុងប្រទេស ដែលនាំមកនូវភាពងាយស្រួលសំរាប់បុគ្គលិកធ្វើការថ្លឹងថ្លែងទៅលើសេចក្តីត្រូវការ នៅទីកន្លែងធ្វើការ និងសេចក្តីត្រូវការថែទាំគ្រួសារនៅផ្ទះ។ បើសិនជាអ្នកមានសំណួរអ្វីមួយ ឬមានអារម្មណ៍ថាអ្នកត្រូវការហើយមានសិទ្ធទទួលបំណាច់ប្រយោជន៍ទាំងនេះ សូមធ្វើការទាក់ទងជាមួយនឹងយើងខ្ញុំនៅក្នុងឺថ្ងនេះ។

1-877-238-4373 (English)
1-877-379-3819 (Español)
1-800-563-2441 (TTY)

P.O. Box 997017
Sacramento, CA 95799-7017

www.edd.ca.gov/eddmail.htm